# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២៩-១២-២០១២ -ព្រះរាជក្រម នស/រកម/១២១២/០១៣ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាអន្តរជាតិស្តីពីនិយតកម្ម នៃការនេសាទបាឡែន និង ពិធីសារ ៤៨៣


### ២~ព្រះរាជក្រឹត្យ


២៩-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១១០៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសព នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៣ រូប ៥០៣

២៩-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១១០៥ ស្តីពី ការបង្កើត សញ្ញាសក្តិ ឯកសណ្ឋាន និង កន្ទាស់រូបសញ្ញាសម្រាប់មន្ត្រីក្របខ័ណ្ឌជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ ៥០៤

២៩-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១១០៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វេហ្គារី ប៉េងអាន** (WEE GARY PENG ANN) ជនជាតិអង់គ្លេស សញ្ជាតិអង់គ្លេស កើតនៅទីក្រុងឡុងដ៏ ចក្រភពអង់គ្លេស ដោយប្តូរឈ្មោះជា **ហុង ឆាយ** (HONG CHHAY) ៥១៦

២៩-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១១០៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្សាំង ប៊ូ** (ZHANG BUOU) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តស៊ីជាំង សាធារណរដ្ឋប្រជាមានិតចិន ៥១៧

២៩-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១១០៨ ស្តីពី ការតែងតាំង ឥស្សរជន ចំនួន ០៤ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្សរ៍ ៥១៨

២៩-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១១១០ ស្តីពី ការដំឡើងឋានៈជូនឯកឧត្តម **ឆាយ យុនម៉ុង** ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភានីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ៥១៩

០២-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០០១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍនី ចំពោះ ឧកញ៉ា **ឈិន ថាវី** សប្បុរសជន នៅខេត្តកំពង់ចាម ៥២០

០២-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០០២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១០ រូប ៥២១

០២-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០០៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីអន្តរក្រសួង ចំនួន ៤៧ រូប ៥២២

០២-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០០៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ឧបាសក **គឹម គៀង** ៥២៤

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១១-០១-២០១៣-អនុក្រឹត្យលេខ ០៧ អនក្រ.បក ស្តីពី ការកាត់ដីទំហំសរុប ១១.៥០០,៥០ ហិកតា នៅស្រុកគាស់ក្រឡ ស្រុកបាណន់ និង ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលក្នុងនោះ កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃរនាមដូនសំ ពីព្រៃសម្បទានយូរីសាគរ និង ពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.៧០៧ គ្រួសារ និង រក្សាទុកមួយចំណែក ជាដីភ្នំ ៥២៥

១១-០១-២០១៣-អនុក្រឹត្យលេខ ០៨ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៤៨៦,៣៨១៣ ហិកតា នៅស្រុកអូយ៉ាដាវ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជា ច័ន្ទរិទ្ធី និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០៤ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង ការផ្តល់សិទ្ធិលើក្បាលដី ៥៣០

១១-០១-២០១៣-អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ២៤៣,៩៩៣២ ហិកតា នៅស្រុកវើនសៃ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៨ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនា សម្ព័ន្ធរូបវ័ន្ត និង ការផ្តល់សិទ្ធិលើក្បាលដី ៥៣៣

១១-០១-២០១៣-អនុក្រឹត្យលេខ ១០ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ២៥៨,១៧៣៣ ហិកតា នៅស្រុកបរកែវ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជា ច័ន្ទរិទ្ធី និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៧ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង ការផ្តល់សិទ្ធិលើក្បាលដី ៥៣៦

១១-០១-២០១៣-អនុក្រឹត្យលេខ ១១ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ១២៨,៤២៩៦ ហិកតា នៅស្រុកវើនសៃ ខេត្តរតនគីរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង ការផ្ដល់សិទ្ធិលើក្បាលដី ៥៣៩

១៣-១១-២០១២-អនុក្រឹត្យលេខ **២៣៨១** ដល់អនុក្រឹត្យលេខ **២៤០៨** អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៤២

## III_ការិយាល័យបណ្ណាក្រសួង

## ១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៤-០១-២០១៣-ប្រកាសលេខ ០០២ សហវ.ប្រក.អគរ ស្ដីពី ការអនុវត្តវិធានបញ្ជាក់ជាមុន ( Advance Ruling ) លើចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ ដើមកំណើតទំនិញ និង តម្លៃគិតពន្ធគយ ៥៧០

## ២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១២-១២-២០១២-ប្រកាសលេខ ១២១១ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្ទីតថេក អ៊ិនដាស្ទ្រាល បង្កើតរោងចក្រ ផលិតកង់ ៥៧២

១២-១២-២០១២-ប្រកាសលេខ ១២១២ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ា ខនគ្រិត ខមភេនី បង្កើតរោងចក្រ ផលិតបេតុងលាយ ៥៧៦

១២-១២-២០១២-ប្រកាសលេខ ១២១៣ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គាវ ដា បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ៥៨០

១២-១២-២០១២-ប្រកាសលេខ ១២១៤ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អិម ធី យេស៊ី ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៥៨៤

## ៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០២-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៥៦៧ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **អេច & អិល គ្រុប** ៥៨៨

០២-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៥៦៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ការិយាល័យតំណាងពាណិជ្ជកម្មក្រុមហ៊ុន **មេនូឡាយហ្វ៍ ហ្វាយនែនសល អេស៊ា លីមីធីត** ៥៩០

០២-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៥៦៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ម៉ាតាសូតា ឌីវេឡុបមេន** ៥៩១

០២-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៩៧០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ទើលដ៍ បេស ហ៊ែលឃែរ** ៥៩៣
០២-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៩៧១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ុនឡេង គ្រុប** ៥៩៥
០២-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៥៨៣ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ស៊ី.អេ.ឌី.អាយ** ៥៩៧
០២-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៥៨៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **លី ហួរ គ្រុប** ៥៩៩
០៣-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៥៨៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ធី-ឡិតស៍** ៦០១

# ព្រះរាជក្រម

នស/រកម/១២១២/០១៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីនិយតកម្មនៃការនេសាទបាឡែន និងពិធីសារ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជា សមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីនិយតកម្ម នៃការនេសាទបាឡែន និងពិធីសារ

**មាត្រា ១.-**

អនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិ ស្តីពីនិយតកម្មនៃការនេសាទបាឡែន ដែលបានអនុម័តនាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៤៦ នៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិក និងបានចូលជាធរមាននាថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៤៨ និងពិធីសារដែលបានអនុម័តនាថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៦ នៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិក ហើយដែលព្រះរាជាណាចក្រកម្ពុជាសុំចូលជាសមាជិកនៃអនុសញ្ញានេះនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ និងបានក្លាយជាសមាជិកពេញសិទ្ធិនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញា និងពិធីសារនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២

នស/រកម.១២១២.០១៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ហត្ថលេខា

ច័ន្ទ សារុន

លេខ [illegible] ១០.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

[illegible]រាជរដ្ឋាភិបាល

សយ សុខា

4/2

# អនុសញ្ញាអន្តរជាតិ
# ស្តីពី
# និយតកម្មនៃការនេសាទបាឡែន
## វ៉ាស៊ីនតោន ថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៤៦

រដ្ឋាភិបាលដែលមានតំណាងស្របច្បាប់ បានចុះហត្ថលេខាយល់ព្រមដូចខាងក្រោម ៖

- ដោយទទួលស្គាល់នូវការយកចិត្តទុកដាក់នៃបណ្តាប្រជាជាតិក្នុងការការពារធនធានធម្មជាតិដ៏ស្តុកស្តម្ភសម្រាប់អនាគតដូចជាផលស្តុកបាឡែន
- ដោយហេតុថា ប្រវត្តិនៃការនេសាទបាឡែនមានលក្ខណៈហួសកម្រិតពីកន្លែងមួយទៅកន្លែងមួយ និងពីប្រភេទមួយទៅប្រភេទមួយទៀត ដែលត្រូវទាមទារចាំបាច់នូវការការពារបាឡែនគ្រប់ប្រភេទពីការធ្វើនេសាទហួសកម្រិត
- ដោយទទួលស្គាល់ថា ផលស្តុកបាឡែនអាចកើនឡើងវិញនៅក្នុងធម្មជាតិ ប្រសិនបើការធ្វើនេសាទមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហើយបរិមាណផលស្តុកនឹងមានការកើនឡើងដែលអាចអនុញ្ញាតឲ្យការនេសាទបាឡែននឹងមិនបង្កគ្រោះថ្នាក់ដល់ធនធានធម្មជាតិ
- ដោយទទួលស្គាល់ ពីផលប្រយោជន៍រួមក្នុងការរក្សាឲ្យបានឆាប់នូវផលស្តុកបាឡែនក្នុងកម្រិតមួយសមស្របដែលអាចធ្វើទៅបាន ដោយមិនឲ្យប៉ះពាល់ដល់វិបត្តិសេដ្ឋកិច្ចនិងចំណីអាហារ
- ដោយទទួលស្គាល់ថា ការសម្រេចឲ្យបាននូវគោលបំណងទាំងនេះ ការនេសាទបាឡែនត្រូវធ្វើឡើងចំពោះតែប្រភេទណាដែលអាចធានាបាននូវនិរន្តរភាពអាជីវកម្ម ដើម្បីទុកចន្លោះពេលឲ្យប្រភេទដែលមានការថយចុះនោះ អាចកើនចំនួនឡើងវិញបាន
- ដោយចង់បង្កើតប្រព័ន្ធនិយតកម្មអន្តរជាតិមួយ សម្រាប់គ្រប់គ្រងការនេសាទបាឡែនក្នុងគោលបំណង ដើម្បីធានាឲ្យបាននូវការអភិរក្សមួយប្រកបដោយប្រសិទ្ធភាពនិងការអភិវឌ្ឍផលស្តុកបាឡែន ដោយផ្អែកលើគោលការណ៍ដែលមានចែងក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីនិយតកម្មនៃការនេសាទបាឡែនដែលបានចុះហត្ថលេខាកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៣៧ នៅទីក្រុងឡុងដ៍និងពិធីសារដែលបានឯកភាពចុះហត្ថលេខាកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៣៨ និងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៤៥ នៅទីក្រុងឡុងដ៍ និង
- បានសម្រេចបង្កើតនូវអនុសញ្ញាមួយ ដោយមានបញ្ចូលនូវការអភិរក្សផលស្តុកបាឡែននិងលទ្ធភាពនៃការអភិវឌ្ឍឧស្សាហកម្មនេសាទបាឡែនមួយសមស្រប
- បានឯកភាពដូចខាងក្រោម ៖

## មាត្រា ១

១- អនុសញ្ញានេះមានភ្ជាប់មកជាមួយនូវតារាងផែនការការងារដែលជាផ្នែកមួយនៃអនុសញ្ញានេះ ។ គ្រប់ឯកសារយោងនៃអនុសញ្ញានេះ ត្រូវយល់ថាមានទាំងតារាងផែនការការងារក្នុងទម្រង់បច្ចុប្បន្នឬក៏ជាការកែសម្រួលបន្ថែមដូចមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា ៥ (ប្រាំ)។

២- អនុសញ្ញានេះត្រូវអនុវត្តចំពោះនាវាដែលមានរោងចក្រ ទីតាំងនៅលើគោក និងមធ្យោបាយចាប់បាឡែនដែលស្ថិតក្រោមយុត្តាធិការនៃរដ្ឋាភិបាលដែលបានចុះកិច្ចសន្យានិងដែនទឹកដែលស្វែងរកបាឡែនដោយនាវាដែលមានរោងចក្រ ទីតាំងលើដីគោក និងមធ្យោបាយចាប់បាឡែន ។

## មាត្រា ២

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់នៅក្នុងអនុសញ្ញានេះ ៖

១- *នាវារោងចក្រ* គឺជានាវាដែលប្រើប្រាស់សម្រាប់កែច្នៃបាឡែនទាំងមូលឬមួយផ្នែកនៅពីលើឬនៅខាងក្នុងនាវានោះ ។

២- *ទីតាំងលើដីគោក* គឺជាទីតាំងដីគោកដែលប្រើប្រាស់សម្រាប់កែច្នៃបាឡែនទាំងមូលឬមួយផ្នែក ។

៣- *មធ្យោបាយចាប់បាឡែន* គឺជានាវាដែលប្រើប្រាស់ក្នុងគោលបំណងប្រមាញ់ ចាប់ សណ្តោង ស្ទូច ឬឈ្លបយកការណ៍ពីបាឡែន ។

៤- *រដ្ឋាភិបាលចុះកិច្ចសន្យា* គឺជារដ្ឋាភិបាលដែលបានផ្តល់សច្ចាប័នឬបានប្រកាសចូលជាសមាជិកអនុសញ្ញានេះ ។

## មាត្រា ៣

១- រដ្ឋាភិបាលចុះកិច្ចសន្យាទាំងអស់ ឯកភាពបង្កើតគណៈកម្មការនេសាទបាឡែនអន្តរជាតិមួយដែលមានសមាសភាពម្នាក់មកពីរដ្ឋាភិបាលចុះកិច្ចសន្យានីមួយៗ ។ សមាជិកនីមួយៗមានសំឡេងបោះឆ្នោតតែមួយគត់ តែអាចអមដោយជំនាញការនិងទីប្រឹក្សាម្នាក់ឬច្រើននាក់ ។

២- គណៈកម្មការត្រូវជ្រើសរើសប្រធានមួយរូបនិងអនុប្រធានមួយរូប ពីក្នុងចំណោមសមាជិករបស់ខ្លួន រួចត្រូវកំណត់របៀបរបបនៃទម្រង់ការងារដោយខ្លួនឯង ។ ការសម្រេចចិត្តរបស់គណៈកម្មការគឺត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតដោយយកសំឡេងគាំទ្រភាគច្រើនដាច់ខាត លើកលែងតែការសម្រេចចិត្តទាំងឡាយណាដែលទាក់ទងនឹងមាត្រា ៥ (ប្រាំ) គឺត្រូវឆ្លងកាត់ការបោះឆ្នោតដោយយកសំឡេងគាំទ្រ៣ភាគ៤ (បីភាគបួន)។ របៀបរបបនៃទម្រង់ការងារត្រូវបានផ្តល់ឲ្យសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត បើពុំនោះទេ គឺត្រូវសម្រេចដោយការប្រជុំនៃគណៈកម្មការ ។

៣- គណៈកម្មការមានសិទ្ធិចាត់តាំងលេខាធិការនិងបុគ្គលិករបស់ខ្លួនផ្ទាល់ ។

៤- គណៈកម្មការអាចបង្កើតគណៈកម្មាធិការនានាតាមការចាំបាច់ ដែលមានសមាសភាពមកពីសមាជិកនិងជំនាញការឬទីប្រឹក្សារបស់ខ្លួន ដើម្បីបំពេញភារកិច្ចដែលគណៈកម្មការប្រគល់ជូន ។

៥- រាល់ការចំណាយរបស់សមាជិកនៃគណៈកម្មការ ជំនាញការ និងទីប្រឹក្សាអមនៃប្រទេសនីមួយៗត្រូវកំណត់ដោយរដ្ឋាភិបាលរបស់ខ្លួន ។

៦- ដោយទទួលស្គាល់ថា ទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិនឹងមានការបារម្ភទៅលើការអភិរក្សនិងអភិវឌ្ឍការនេសាទបាឡែន និងផលិតផលដែលបានមកពីការនេសាទនេះនិងដោយចង់បំបាត់ការជាន់ភារកិច្ចគ្នា រដ្ឋាភិបាលចុះកិច្ចសន្យាទាំងអស់ត្រូវធ្វើការពិភាក្សាគ្នាក្នុងរយៈពេល០២ (ពីរ)ឆ្នាំក្រោយពីអនុសញ្ញានេះចូលជាធរមាន ដើម្បីសម្រេចថាតើគណៈកម្មការនេះគួរបញ្ចូលទៅក្នុងក្របខ័ណ្ឌការងារនៃទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិឬយ៉ាងណា ។

៧- នៅពេលជាមួយគ្នានេះ រដ្ឋាភិបាលនៃចក្រភពអង់គ្លេសនិងអៀកឡង់ខាងជើង (Northern Ireland) ត្រូវរៀបចំពិភាក្សាជាមួយរដ្ឋាភិបាលចុះកិច្ចសន្យា ដើម្បីដំណើរការប្រជុំគណៈកម្មការលើកទី ១ (មួយ) ដោយចាប់ផ្តើមពិគ្រោះយោបល់ដូចមានចែងនៅក្នុងចំណុច ៦ (ប្រាំមួយ) ខាងលើ ។

៨- ការប្រជុំគណៈកម្មការបន្តបន្ទាប់ទៀតនឹងត្រូវកំណត់ដោយគណៈកម្មការ ។

## មាត្រា ៤

១- គណៈកម្មការអាចសហការជាមួយឬតាមរយៈភ្នាក់ងារឯកទេសរបស់រដ្ឋាភិបាលចុះកិច្ចសន្យាឬភ្នាក់ងារសាធារណៈឬភ្នាក់ងារឯកជនឬស្ថាប័នឬអង្គការឬដោយឯករាជ្យដើម្បី ៖

ក- ជំរុញ ផ្តល់យោបល់ឬរៀបចំធ្វើការសិក្សានិងអង្កេតបាឡែននិងការនេសាទបាឡែន ប្រសិនបើមានការចាំបាច់

ខ- ប្រមូលនិងវិភាគព័ត៌មានស្ថិតិពាក់ព័ន្ធនឹងស្ថានភាពបច្ចុប្បន្ននិងនិន្នាការនៃផលស្តុកបាឡែននិងឥទ្ធិពលនៃការនេសាទបាឡែនមកលើផលស្តុក និង

គ- សិក្សាវាយតម្លៃនិងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការថែរក្សានិងបង្កើនចំនួនផលស្តុកបាឡែនឡើងវិញ ។

២- គណៈកម្មការត្រូវរៀបចំបោះពុម្ពរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួន និងអាចបោះពុម្ពដោយឯករាជ្យឬសហការជាមួយនាយកដ្ឋានស្ថិតិបាឡែនអន្តរជាតិនៅទីក្រុង Sandefjord ប្រទេសន័រវេ និងជាមួយអង្គការនិងទីភ្នាក់ងារផ្សេងៗទៀតនូវរបាយការណ៍ដែលគណៈកម្មការយល់ថាសមស្របដូចជាព័ត៌មានស្ថិតិ ព័ត៌មានវិទ្យាសាស្ត្រ និងព័ត៌មានដែលទាក់ទងនឹងបាឡែននិងការនេសាទបាឡែន ។

## មាត្រា ៥

១- គណៈកម្មការអាចធ្វើវិសោធនកម្មជាបន្តបន្ទាប់នូវបទប្បញ្ញត្តិនៃតារាងផែនការការងារ ដែលបានអនុម័តទៅលើនិយតកម្មដោយធ្វើយ៉ាងណាមិនឲ្យប៉ះពាល់ដល់ការអភិរក្ស និងការប្រើប្រាស់ធនធានបាឡែនដោយកែសម្រួល ៖

ក- ប្រភេទដែលត្រូវការពារនិងប្រភេទដែលមិនត្រូវការពារ

ខ- រដូវបិទនិងបើកនេសាទ

គ- តំបន់ដែលអនុញ្ញាតនិងមិនអនុញ្ញាតឲ្យនេសាទដោយមានទាំងការជ្រើសរើសបង្កើតតំបន់អភិរក្សផង

ឃ- កំណត់ទំហំនៃប្រភេទនីមួយៗ

ង- ពេលវេលា វិធីសាស្ត្រ និងកម្លាំងនៃការនេសាទបាឡែន (រួមបញ្ចូលទាំងផលចាប់អតិបរមានៅក្នុងរដូវនីមួយៗ)

ច- បញ្ជាក់ឲ្យបានច្បាស់លាស់នូវប្រភេទឧបករណ៍នេសាទ គ្រឿងបរិក្ខារ និងសម្ភារផ្សេងៗដែលប្រើប្រាស់ដោយចរន្តអគ្គិសនីសម្រាប់នេសាទបាឡែន

ឆ- វិធីសាស្ត្រនៃការវាស់វែង និង

ជ- កំណត់ត្រាលម្អិតស្តីពីផលនេសាទ មធ្យោបាយនេសាទ ព័ត៌មានវិទ្យាសាស្ត្រ និងលក្ខណៈជីវសាស្ត្រផ្សេងៗទៀតដែលពាក់ព័ន្ធ ។

២- ការធ្វើវិសោធនកម្មនៃតារាងផែនការការងារគឺ ៖

ក- ត្រូវធ្វើជាចាំបាច់ដើម្បីសម្រេចនូវគោលបំណងនិងគោលដៅនៃអនុសញ្ញានេះ និងដើម្បីផ្តល់ដល់ការអភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានបាឡែនឲ្យបានសមស្រប

ខ- ត្រូវផ្អែកលើលទ្ធផលនៃការស្រាវជ្រាវវិទ្យាសាស្ត្រ

គ- មិនចាំបាច់កំរិតចំនួនឬសញ្ជាតិនៃនាវា រោងចក្រឬទីតាំងលើដីគោក និងមិនត្រូវបែងចែកចំនួនកូតាទៅលើរោងចក្រឬនាវា ឬទីតាំងលើដីគោក ឬចំនួនក្រុមនាវាដែលមានរោងចក្រ ឬក្រុមទីតាំងលើដីគោក និង

ឃ- ត្រូវយកចិត្តទុកដាក់ខ្ពស់ទៅលើផលប្រយោជន៍នៃអ្នកប្រើប្រាស់ផលិតផលបាឡែននិងឧស្សាហកម្មនេសាទបាឡែន ។

៣- វិសោធនកម្មនីមួយៗនឹងចូលជាធរមានក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីគណៈកម្មការធ្វើសេចក្តីជូនដំណឹងស្តីពីវិសោធនកម្មនេះជូនដល់រដ្ឋាភិបាលចុះកិច្ចសន្យានីមួយៗលើកលែងតែ ៖

ក- បើរដ្ឋាភិបាលណាមួយផ្តល់ការជំទាស់លើវិសោធនកម្មទៅគណៈកម្មការក្នុងរយៈពេលកំណត់ ៩០ (កៅសិប)ថ្ងៃ នោះវិសោធនកម្មនេះនឹងមិនមានសុពលភាពទៅលើរដ្ឋាភិបាលណាមួយទេក្នុងរយៈពេលកំណត់ ៩០ (កៅសិប)ថ្ងៃបន្ថែមទៀត

ខ- នៅពេលនោះ បើមានរដ្ឋាភិបាលចុះកិច្ចសន្យាផ្សេងទៀតផ្តល់ការជំទាស់លើវិសោធនកម្មនេះនៅក្នុងរយៈពេលកំណត់៩០ (កៅសិប) ថ្ងៃបន្ថែមនេះ ឬមុនពេលកំណត់៣០ (សាមសិប)ថ្ងៃចាប់ពីថ្ងៃទទួលបានការជំទាស់ចុងក្រោយ ដូចនេះរយៈពេលកំណត់៩០ (កៅសិប)ថ្ងៃបន្ថែមដែលវិសោធនកម្មនេះនឹងមានសុពលភាពគឺគិតចាប់ពីថ្ងៃទទួលបានលិខិតក្រោយបំផុត និង

គ- បន្ទាប់ពីនោះមក វិសោធនកម្មនេះនឹងមានសុពលភាពចំពោះរដ្ឋាភិបាលចុះកិច្ចសន្យាណាដែលមិនមានការជំទាស់ ប៉ុន្តែនឹងមិនមានសុពលភាពចំពោះរដ្ឋាភិបាលណាដែលនៅតែជំទាស់រហូតដល់ថ្ងៃដែលការជំទាស់នេះត្រូវបានដកចេញ ។ គណៈកម្មការត្រូវប្រញាប់ធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋាភិបាលចុះកិច្ចសន្យាទាំងអស់នៅពេលបានទទួលបានការជំទាស់ និងការដកចេញនីមួយៗ ហើយរដ្ឋាភិបាលចុះកិច្ចសន្យានីមួយៗត្រូវឆ្លើយតបវិញនៅពេលបានទទួលសេចក្តីជូនដំណឹងស្តីពីវិសោធនកម្មនៃការជំទាស់ និងការដកចេញនូវការជំទាស់ទាំងអស់នោះ ។

៤- មិនមានវិសោធនកម្មណាមួយមានសុពលភាពនៅមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៤៩ ទេ ។

## មាត្រា ៦

គណៈកម្មការអាចផ្តល់អនុសាសន៍ជាបន្តបន្ទាប់ទៅរដ្ឋាភិបាលចុះកិច្ចសន្យាណាមួយ ឬទាំងអស់ចំពោះបញ្ហាណាមួយដែលពាក់ព័ន្ធទៅនឹងបាឡែនឬការនេសាទបាឡែន ព្រមទាំងគោលបំណងនិងគោលដៅនៃអនុសញ្ញានេះ ។

## មាត្រា ៧

រដ្ឋាភិបាលចុះកិច្ចសន្យាត្រូវធានាបញ្ជូនសារជាប្រញាប់ទៅនាយកដ្ឋានស្ថិតិបាឡែនអន្តរជាតិនៅទីក្រុង Sandefjord ប្រទេសន័រវេសឬទៅស្ថាប័នដទៃទៀតដែលគណៈកម្មការកំណត់ជាផ្លូវការ ដោយផ្តល់នូវសេចក្តីជូនដំណឹង ព័ត៌មានស្ថិតិ និងព័ត៌មានដទៃទៀតទៅតាមតម្រូវការនៃអនុសញ្ញានេះ ទៅតាមរបៀបរបបនិងទម្រង់ដែលអនុម័តដោយគណៈកម្មការ ។

## មាត្រា ៨

១- ដូចមានចែងនៅក្នុងអនុសញ្ញានេះ រដ្ឋាភិបាលចុះកិច្ចសន្យានីមួយៗអាចផ្តល់ការអនុញ្ញាតពិសេសឲ្យជនជាតិរបស់ខ្លួនសម្លាប់ ចាប់ និងបង្ហាត់បាឡែនក្នុងគោលដៅនៃការស្រាវជ្រាវវិទ្យាសាស្ត្រដោយកំណត់ចំនួនបាឡែននិងក្នុងល័ក្ខខ័ណ្ឌផ្សេងទៀតដែលរដ្ឋាភិបាលចុះកិច្ចសន្យានោះគិតថាសមស្រប ហើយការសម្លាប់ ការចាប់ និងការបង្ហាត់បាឡែនដូចមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រានេះមិនស្ថិតក្រោមការអនុវត្តនៃអនុសញ្ញានេះទេ ។ រដ្ឋាភិបាលចុះកិច្ចសន្យានីមួយៗត្រូវធ្វើរបាយការណ៍មកគណៈកម្មការជាបន្ទាន់នូវការអនុញ្ញាតពិសេសដែលខ្លួនបានផ្តល់ ។ រដ្ឋាភិបាលចុះកិច្ចសន្យានីមួយៗអាចដកហូតឬលុបចោលគ្រប់ពេលទាំងអស់នូវលិខិតអនុញ្ញាតពិសេសដែលខ្លួនបានផ្តល់ ។

២- ចំនួនបាឡែនដែលចាប់បាននៅក្រោមការអនុញ្ញាតពិសេសនេះ ត្រូវកែច្នៃទៅតាមគោលការណ៍ ហើយគោលការណ៍កែច្នៃនីមួយៗ ត្រូវយោងទៅតាមការសម្រេចរបស់រដ្ឋាភិបាលដែលបានចេញលិខិតអនុញ្ញាតពិសេសនោះ ។

៣- រដ្ឋាភិបាលចុះកិច្ចសន្យានីមួយៗ ត្រូវផ្តល់ព័ត៌មានវិទ្យាសាស្ត្រដែលពាក់ព័ន្ធនឹងបាឡែននិងការនេសាទបាឡែនដែលខ្លួនរកឃើញ រួមទាំងលទ្ធផលនៃការស្រាវជ្រាវដូចមានចែងក្នុងកថាខណ្ឌទី១ (មួយ) នៃមាត្រានេះនិងមាត្រា ៤ (បួន) ទៅស្ថាប័នដែលគណៈកម្មការចង្អុលបង្ហាញតាមទម្លាប់អនុវត្តកន្លងមកក្នុងរយៈពេលមិនឲ្យលើសពី ១ (មួយ) ឆ្នាំ។

៤- ដោយទទួលស្គាល់ថា ការបន្តប្រមូលនិងវិភាគទិន្នន័យជីវសាស្ត្រពាក់ព័ន្ធនឹងដំណើរការនៃនាវាផងចក្រនិងទីតាំងលើដីគោក ជាការចាំបាច់មិនអាចខ្វះបានសម្រាប់គ្រប់គ្រងការនេសាទបាឡែនឲ្យបានល្អប្រសើរ ។ រដ្ឋាភិបាលចុះកិច្ចសន្យាត្រូវប្រើគ្រប់វិធានការចាំបាច់ដើម្បីទទួលបានទិន្នន័យទាំងនេះ ។

## មាត្រា ៩

១- រដ្ឋាភិបាលចុះកិច្ចសន្យា ត្រូវចាត់វិធានការសមស្រប ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញា នេះនិងការដាក់ទណ្ឌកម្មដល់បុគ្គលឬនាវាដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួនដែលបានប្រព្រឹត្តបទល្មើសផ្ទុយនឹងបទប្បញ្ញត្តិទាំងនេះ ។

២- មិនមានប្រាក់បន្ថែមឬរង្វាន់ផ្សេងៗជូនអ្នកប្រមាញ់និងនាវិកនៃនាវានេសាទបាឡែនដែលនេសាទបាឡែនទាំងឡាយណាដែលហាមឃាត់ដោយអនុសញ្ញានេះទេ ។

៣- ជនណាដែលប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ត្រូវផ្តន្ទាទោសដោយរដ្ឋាភិបាលដែលមានយុត្តាធិការលើការរំលោភនេះ ។

៤- រដ្ឋាភិបាលចុះកិច្ចសន្យានីមួយៗត្រូវរាយការណ៍ពីករណីបទល្មើសដែលប្រព្រឹត្តដោយបុគ្គលឬនាវាដែលស្ថិតនៅក្រោមយុត្តាធិការខ្លួនទៅគណៈកម្មការដោយអធិប្បាយលម្អិតទៅលើករណីប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះដោយយោងតាមរបាយការណ៍ដែលបានរាយការណ៍ដោយមន្ត្រីអធិការកិច្ចរបស់ខ្លួនបានផ្តល់ឲ្យ ។ ព័ត៌មានដែលភ្ជាប់ទៅជាមួយនេះត្រូវបញ្ជាក់ពីវិធានការទៅលើបទល្មើសនិងការពិន័យដែលខ្លួនបានសម្រេច ។

## មាត្រា ១០

១- ឯកសារផ្លូវការនៃការផ្តល់សច្ចាប័នលើអនុសញ្ញានេះ ត្រូវបញ្ជូនទៅតម្កល់ទុកនៅរដ្ឋាភិបាលសហរដ្ឋអាមេរិក ។

២- រដ្ឋាភិបាលណាដែលមិនបានចុះហត្ថលេខាលើអនុសញ្ញានេះ អាចចូលជាសមាជិកបានក្រោយពេលដែលអនុសញ្ញានេះចូលជាធរមាន ដោយសរសេរលិខិតជាផ្លូវការទៅរដ្ឋាភិបាលសហរដ្ឋអាមេរិក ។

៣- រដ្ឋាភិបាលសហរដ្ឋអាមេរិកត្រូវជូនដំណឹងទៅរដ្ឋាភិបាលដែលជាភាគីហត្ថលេខីនិងរដ្ឋាភិបាលដែលជាសមាជិកទាំងអស់នូវរាល់ឯកសារផ្លូវការដែលបានតម្កល់ទុកនិងឯកសារផ្លូវការដែលបានទទួល ។

៤- អនុសញ្ញានេះនឹងចូលជាធរមាននៅពេលដែលមានរដ្ឋាភិបាលយ៉ាងតិច ០៦(ប្រាំមួយ) រួមទាំងរដ្ឋាភិបាលនៃប្រទេសហូឡង់ ន័រវេ សហភាពសាធារណៈរដ្ឋសង្គមនិយមសូវៀត ចក្រភពអង់គ្លេសនិងអៀកឡង់ខាងជើង និងសហរដ្ឋអាមេរិកបានដាក់ឯកសារជាផ្លូវការនៃការផ្តល់សច្ចាប័ន ហើយនឹងចូលជាធរមានភ្លាមចំពោះរដ្ឋាភិបាលណាដែលបានផ្តល់សច្ចាប័នឬចូលជាសមាជិកគិតចាប់ពីថ្ងៃដែលបានតម្កល់ឯកសារជាផ្លូវការឬទទួលឯកសារសុំចូលជាសមាជិករបស់រដ្ឋាភិបាលនោះ ។

៥- បទប្បញ្ញត្តិនៃតារាងផែនការការងារ មិនត្រូវអនុវត្តមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៤៨ ទេ ហើយវិសោធនកម្មលើតារាងផែនការការងារដែលបានអនុម័តក្នុងមាត្រា៥(ប្រាំ) ក៏មិនត្រូវអនុវត្តមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៤៩ ដែរ ។

## មាត្រា ១១

រដ្ឋាភិបាលនីមួយៗអាចលាលែងពីសមាជិកភាពនៃអនុសញ្ញានេះនៅមុនថ្ងៃទី៣០ ខែមិថុនាជារៀងរាល់ឆ្នាំ ដោយធ្វើលិខិតជាលាយលក្ខណ៍អក្សរជូនរដ្ឋាភិបាលតម្កល់ឯកសារនៅថ្ងៃឬមុនថ្ងៃទី០១ ខែមករានៃឆ្នាំដដែល។ ក្រោយពីទទួលបានលិខិតនេះ រដ្ឋាភិបាលតម្កល់ឯកសារត្រូវជូនដំណឹងទៅរដ្ឋាភិបាលចុះកិច្ចសន្យាដទៃទៀតភ្លាម ។ រដ្ឋាភិបាលចុះកិច្ចសន្យាដទៃទៀតអាចធ្វើរបៀបនេះ ក្នុងរយៈពេលមួយខែនៃការទទួលបានសេចក្តីជូនដំណឹងចម្លងពីរដ្ឋាភិបាលតម្កល់ឯកសារស្តីពីការលាលែងពីសមាជិកភាពនៃអនុសញ្ញានេះ ហើយអនុសញ្ញានេះឈប់មានសុពលភាពទៅលើរដ្ឋាភិបាលដែលប្រកាសលាលែងនេះនៅថ្ងៃទី៣០ (សាមសិប) ខែមិថុនា នៃឆ្នាំដដែល ។

អនុសញ្ញានេះត្រូវបានកំណត់ពេលបើកចំហសម្រាប់ចុះហត្ថលេខា ។ រយៈពេលបើកចំហសម្រាប់ចុះហត្ថលេខាមានរយៈពេល១៤ (ដប់បួន) ថ្ងៃចាប់ពីថ្ងៃនេះតទៅ ។

សាក្សីដែលបានចុះហត្ថលេខាដូចខាងក្រោមនេះ បានផ្តល់សិទ្ធិស្របច្បាប់ចំពោះការចុះហត្ថលេខាលើអនុសញ្ញានេះ ។

ធ្វើនៅរដ្ឋធានីវ៉ាស៊ីនតោននាថ្ងៃទីពីរ ខែធ្នូ ឆ្នាំមួយពាន់ប្រាំបួនរយសែសិបប្រាំមួយ។ ច្បាប់ដើមនៃអនុសញ្ញានេះជាភាសាអង់គ្លេស ត្រូវតម្កល់ទុកនៅរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកត្រូវបញ្ជូនឯកសារថតចម្លងដោយមានបញ្ជាក់ជាផ្លូវការទៅរដ្ឋាភិបាលភាគីហត្ថលេខីនិងរដ្ឋាភិបាលដែលចូលជាសមាជិក ។

## ហត្ថលេខី

១- សម្រាប់ប្រទេសឈីលី (Chile): Augustin R. Edwards

២- សម្រាប់ប្រទេសប៉េរូ (Peru): Carlos Rotalde

៣- សម្រាប់ប្រទេសអាហ្សង់ទីន (Argentina): Oscar Ivanissevich, José Manuel Moneta, Guillermo Brown, Pedro H. Bruno Videla

៤- សម្រាប់ប្រទេសដាណឺម៉ាក (Denmark): Peter Friedrich Erichsen

៥- សម្រាប់សហភាពសាធារណៈរដ្ឋសង្គមនិយមសូវៀត (The Union of Soviet Socialist Republics): Alexander S. Bogdanov, Eugine I. Nikishin

៦- សម្រាប់ប្រទេសអូស្ត្រាលី (Australia): Francis F. Anderson

៧- សម្រាប់ប្រទេសបារាំង (France): Francis Lacoste

៨- សម្រាប់ចក្រភពអង់គ្លេសនិងប្រទេសអៀកឡង់ខាងជើង (The United Kingdom of Great Britain and Northern Ireland): A.T.A. Dobson, J. Thomson

៩- សម្រាប់ប្រទេសប្រេស៊ីល (Brazil): Paulo Fróes da Cruz

១០- សម្រាប់ប្រទេសហូឡង់ (The Netherlands): Guy Richardson Powles

១១- សម្រាប់សហរដ្ឋអាមេរិក (The United States of America): Remington Kellogg, Ira N. Gabrielson, William E.S. Flory

១២- សម្រាប់ប្រទេសកាណាដា (Canada): H.H. Wrong, H.A. Scott

១៣- សម្រាប់ប្រទេសញ៉ូវហ្សេលែន (New Zealand): Birger Bergersen

១៤- សម្រាប់សហព័ន្ធអាហ្វ្រិកខាងត្បូង (The Union of South Africa): H.T. Andrews

# International Convention For The Regulation of Whaling

**Washington, 2nd December, 1946**

The Governments whose duly authorised representatives have subscribed hereto,

Recognizing the interest of the nations of the world in safeguarding for future generations the great natural resources represented by the whale stocks;

Considering that the history of whaling has seen over-fishing of one area after another and of one species of whale after another to such a degree that it is essential to protect all species of whales from further over-fishing;

Recognizing that the whale stocks are susceptible of natural increases if whaling is properly regulated, and that increases in the size of whale stocks will permit increases in the number of whales which may be captured without endangering these natural resources;

Recognizing that it is in the common interest to achieve the optimum level of whale stocks as rapidly as possible without causing widespread economic and nutritional distress;

Recognizing that in the course of achieving these objectives, whaling operations should be confined to those species best able to sustain exploitation in order to give an interval for recovery to certain species of whales now depleted in numbers;

Desiring to establish a system of international regulation for the whale fisheries to ensure proper and effective conservation and development of whale stocks on the basis of the principles embodied in the provisions of the International Agreement for the Regulation of Whaling, signed in London on 8th June, 1937, and the protocols to that Agreement signed in London on 24th June, 1938, and 26th November, 1945; and

Having decided to conclude a convention to provide for the proper conservation of whale stocks and thus make possible the orderly development of the whaling industry;

Have agreed as follows:-

## Article 1

1. This Convention includes the Schedule attached thereto which forms an integral part thereof. All references to "Convention" shall be understood as including the said Schedule either in its present terms or as amended in accordance with the provisions of Article V.
2. This Convention applies to factory ships, land stations, and whale catchers under the jurisdiction of the Contracting Governments and to all waters in which whaling is prosecuted by such factory ships, land stations, and whale catchers.

## Article 2

As used in this Convention:-

1. "Factory ship" means a ship in which or on which whales are treated either wholly or in part;

2. "Land station" means a factory on the land at which whales are treated whether wholly or in part;

3. "Whale catcher" means a ship used for the purpose of hunting, taking, towing, holding on to, or scouting for whales;

4. "Contracting Government" means any Government which has deposited an instrument of ratification or has given notice of adherence to this Convention.

## Article 3

1. The Contracting Governments agree to establish an International Whaling Commission, hereinafter referred to as the Commission, to be composed of one member from each Contracting Government. Each member shall have one vote and may be accompanied by one or more experts and advisers.

2. The Commission shall elect from its own members a Chairman and Vice-Chairman and shall determine its own Rules of Procedure. Decisions of the Commission shall be taken by a simple majority of those members voting except that a three-fourths majority of those members voting shall be required for action in pursuance of Article V. The Rules of Procedure may provide for decisions otherwise than at meetings of the Commission.

3. The Commission may appoint its own Secretary and staff.

4. The Commission may set up, from among its own members and experts or advisers, such committees as it considers desirable to perform such functions as it may authorize.

5. The expenses of each member of the Commission and of his experts and advisers shall be determined by his own Government.

6. Recognizing that specialized agencies related to the United Nations will be concerned with the conservation and development of whale fisheries and the products arising therefrom and desiring to avoid duplication of functions, the Contracting Governments will consult among themselves within two years after the coming into force of this Convention to decide whether the Commission shall be brought within the framework of a specialized agency related to the United Nations.

7. In the meantime the Government of the United Kingdom of Great Britain and Northern Ireland shall arrange, in consultation with the other Contracting Governments, to convene the first meeting of the Commission, and shall initiate the consultation referred to in paragraph 6 above.

8. Subsequent meetings of the Commission shall be convened as the Commission may determine.

## Article 4

1. The Commission may either in collaboration with or through independent agencies of the Contracting Governments or other public or private agencies, establishments, or organizations, or independently; (a) encourage, recommend, or if necessary, organize studies and investigations relating to whales and whaling; (b)collect and analyze statistical information concerning the current condition and trend of the whale stocks and the effects of whaling activities thereon; (c)study, appraise, and disseminate information concerning methods of maintaining and increasing the populations of whale stocks.

2. The Commission shall arrange for the publication of reports of its activities, and it may publish independently or in collaboration with the International Bureau for Whaling Statistics at Sandefjord in Norway and other organizations and agencies such reports as it deems appropriate, as well as statistical, scientific, and other pertinent information relating to whales and whaling.

## Article 5

1. The Commission may amend from time to time the provisions of the Schedule by adopting regulations with respect to the conservation and utilization of whale resources, fixing (a) protected and unprotected species; (b) open and closed seasons; (c) open and closed waters, including the designation of sanctuary areas; (d) size limits for each species; (e) time, methods, and intensity of whaling (including the maximum catch of whales to be taken in any one season); (f) types and specifications of gear and apparatus and appliances which may be used; (g) methods of measurement; and (h) catch returns and other statistical and biological records.

2. These amendments of the Schedule (a) shall be such as are necessary to carry out the objectives and purposes of this Convention and to provide for the conservation, development, and optimum utilization of the whale resources; (b) shall be based on scientific findings; (c) shall not involve restrictions on the number or nationality of factory ships or land stations, nor allocate specific quotas to any factory or ship or land station or to any group of factory ships or land stations; and (d) shall take into consideration the interests of the consumers of whale products and the whaling industry.

3. Each of such amendments shall become effective with respect to the Contracting Governments ninety days following notification of the amendment by the Commission to each of the Contracting Governments, except that (a) if any Government presents to the Commission objection to any amendment prior to the expiration of this ninety-day period, the amendment shall not become effective with respect to any of the Governments for an additional ninety days; (b) thereupon, any other Contracting Government may present objection to the amendment at any time prior to the expiration of the additional ninety-day period, or before the expiration of thirty days from the date of receipt of the last objection received during such additional ninety-day period, whichever date shall be the later; and (c) thereafter, the amendment shall become effective with respect to all Contracting Governments which have not presented objection but shall not become effective with respect to any Government which has so objected until such date as the objection is withdrawn. The Commission shall notify each Contracting Government

immediately upon receipt of each objection and withdrawal and each Contracting Government shall acknowledge receipt of all notifications of amendments, objections, and withdrawals.

4. No amendments shall become effective before 1st July, 1949.

## Article 6

The Commission may from time to time make recommendations to any or all Contracting Governments on any matters which relate to whales or whaling and to the objectives and purposes of this Convention.

## Article 7

The Contracting Government shall ensure prompt transmission to the International Bureau for Whaling Statistics at Sandefjord in Norway, or to such other body as the Commission may designate, of notifications and statistical and other information required by this Convention in such form and manner as may be prescribed by the Commission.

## Article 8

1. Notwithstanding anything contained in this Convention any Contracting Government may grant to any of its nationals a special permit authorizing that national to kill, take and treat whales for purposes of scientific research subject to such restrictions as to number and subject to such other conditions as the Contracting Government thinks fit, and the killing, taking, and treating of whales in accordance with the provisions of this Article shall be exempt from the operation of this Convention. Each Contracting Government shall report at once to the Commission all such authorizations which it has granted. Each Contracting Government may at any time revoke any such special permit which it has granted.

2. Any whales taken under these special permits shall so far as practicable be processed and the proceeds shall be dealt with in accordance with directions issued by the Government by which the permit was granted.

3. Each Contracting Government shall transmit to such body as may be designated by the Commission, in so far as practicable, and at intervals of not more than one year, scientific information available to that Government with respect to whales and whaling, including the results of research conducted pursuant to paragraph 1 of this Article and to Article IV.

4. Recognizing that continuous collection and analysis of biological data in connection with the operations of factory ships and land stations are indispensable to sound and constructive management of the whale fisheries, the Contracting Governments will take all practicable measures to obtain such data.

## Article 9

1. Each Contracting Government shall take appropriate measures to ensure the application of the provisions of this Convention and the punishment of infractions against the said provisions in operations carried out by persons or by vessels under its jurisdiction.

2. No bonus or other remuneration calculated with relation to the results of their work shall be paid to the gunners and crews of whale catchers in respect of any whales the taking of which is forbidden by this Convention.

3. Prosecution for infractions against or contraventions of this Convention shall be instituted by the Government having jurisdiction over the offence.

4. Each Contracting Government shall transmit to the Commission full details of each infraction of the provisions of this Convention by persons or vessels under the jurisdiction of that Government as reported by its inspectors. This information shall include a statement of measures taken for dealing with the infraction and of penalties imposed.

## Article 10

1. This Convention shall be ratified and the instruments of ratifications shall be deposited with the Government of the United States of America.

2. Any Government which has not signed this Convention may adhere thereto after it enters into force by a notification in writing to the Government of the United States of America.

3. The Government of the United States of America shall inform all other signatory Governments and all adhering Governments of all ratifications deposited and adherences received.

4. This Convention shall, when instruments of ratification have been deposited by at least six signatory Governments, which shall include the Governments of the Netherlands, Norway, the Union of Soviet Socialist Republics, the United Kingdom of Great Britain and Northern Ireland, and the United States of America, enter into force with respect to those Governments and shall enter into force with respect to each Government which subsequently ratifies or adheres on the date of the deposit of its instrument of ratification or the receipt of its notification of adherence.

5. The provisions of the Schedule shall not apply prior to 1st July, 1948. Amendments to the Schedule adopted pursuant to Article V shall not apply prior to 1st July, 1949.

## Article 11

Any Contracting Government may withdraw from this Convention on 30th June, of any year by giving notice on or before 1st January, of the same year to the depository Government, which upon receipt of such a notice shall at once communicate it to the other Contracting Governments. Any other Contracting Government may, in like manner, within one month of the receipt of a copy of such a notice from the depository Government give notice of withdrawal, so that the Convention shall cease to be in force on 30th June, of the same year with respect to the Government giving such notice of withdrawal.

The Convention shall bear the date on which it is opened for signature and shall remain open for signature for a period of fourteen days thereafter.

In witness whereof the undersigned, being duly authorized, have signed this Convention.

Done in Washington this second day of December, 1946, in the English language, the original of which shall be deposited in the archives of the Government of the United States of America. The Government of the United States of America shall transmit certified copies thereof to all the other signatory and adhering Governments.

**SIGNATORIES:**

- FOR CHILE: Augustín R. Edwards
- FOR PERU: Carlos Rotalde
- FOR ARGENTINA: Oscar Ivanissevich, José Manuel Moneta, Guillermo Brown, Pedro H. Bruno Videla
- FOR DENMARK: Peter Friedrich Erichsen
- FOR THE UNION OF SOVIET SOCIALIST REPUBLICS: Alexander S. Bogdanov, Eugine I. Nikishin
- FOR AUSTRALIA: Francis F. Anderson
- FOR FRANCE: Francis Lacoste
- FOR THE UNITED KINGDOM OF GREAT BRITAIN AND NORTHERN IRELAND: A.T.A. Dobson, J. Thomson
- FOR BRAZIL: Paulo Fróes da Cruz
- FOR THE NETHERLANDS: Guy Richardson Powles
- FOR THE UNITED STATES OF AMERICA: Remington Kellogg, Ira N. Gabrielson, William E.S. Flory
- FOR CANADA: H.H. Wrong, H.A. Scott
- FOR NEW ZEALAND: Birger Bergersen
- FOR THE UNION OF SOUTH AFRICA: H.T. Andrews

# ពិធីសារ

## វ៉ាស៊ីនតោន ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៥៦

ពិធីសារនៃអនុសញ្ញាអន្តរជាតិស្តីពីនិយតកម្មនៃការនេសាទបាឡែនដែលបានចុះហត្ថលេខានៅរដ្ឋធានីវ៉ាស៊ីនតោន នាថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៤៦

រដ្ឋាភិបាលចុះកិច្ចសន្យាលើអនុសញ្ញាអន្តរជាតិស្តីពីនិយតកម្មនៃការនេសាទបាឡែនដែលបានចុះហត្ថលេខានៅរដ្ឋធានីវ៉ាស៊ីនតោននាថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៤៦ ដែលចាប់ពីពេលនេះតទៅហៅថា អនុសញ្ញានេសាទបាឡែនឆ្នាំ១៩៤៦ ដោយចង់ពង្រីកការអនុវត្តអនុសញ្ញានេះទៅដល់ឧទ្ធម្ភាគចក្រនិងយន្តហោះផ្សេងៗនិងដើម្បីបញ្ចូលបទប្បញ្ញត្តិស្តីពីវិធីសាស្ត្រនៃការធ្វើអធិការកិច្ចទៅក្នុងចំណោមបទប្បញ្ញត្តិទាំងអស់នៃតារាងផែនការការងារដែលត្រូវធ្វើវិសោធនកម្មដោយគណៈកម្មការបានឯកភាពដូចតទៅ ៖

### មាត្រា ១

កថាខណ្ឌទី៣ ក្នុងមាត្រា២ នៃអនុសញ្ញានេសាទបាឡែនឆ្នាំ១៩៤៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖ "៣" មធ្យោបាយចាប់បាឡែនមានឧទ្ធម្ភាគចក្រឬយន្តហោះផ្សេងឬនាវាដែលប្រើក្នុងគោលបំណងប្រមាញ់ ចាប់ សម្លាប់ សណ្តោង ស្ទូចឬឈ្លបយកការណ៍ពីបាឡែន ។

### មាត្រា ២

វាក្យខណ្ឌទី១ ក្នុងមាត្រា៥ នៃអនុសញ្ញានេសាទបាឡែនឆ្នាំ១៩៤៦ ត្រូវបានធ្វើវិសោធនកម្មដោយលុបពាក្យ "និង" នៅខាងចុងវាក្យខណ្ឌនៃចំនុច (ឆ) ជំនួសវិញដោយ " និង " នៅខាងចុងវាក្យខណ្ឌនៃចំនុច (ជ) និងបន្ថែមចំនុច (ឈ) ដូចតទៅ " វិធីសាស្ត្រនៃការធ្វើអធិការកិច្ច " ។

### មាត្រា ៣

១- ពិធីសារនេះត្រូវបានបើកចំហសម្រាប់ចុះហត្ថលេខានិងផ្តល់សច្ចាប័នឬក៏ចូលជាសមាជិកក្នុងនាមរដ្ឋាភិបាលចុះកិច្ចសន្យាណាមួយរបស់អនុសញ្ញានេសាទបាឡែនឆ្នាំ១៩៤៦ ។

២- ពិធីសារនេះនឹងចូលជាធរមាននៅថ្ងៃដែលឯកសារផ្លូវការនៃការផ្តល់សច្ចាប័នឬទទួលបានលិខិតជាផ្លូវការដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកក្នុងនាមឲ្យរដ្ឋាភិបាលចុះកិច្ចសន្យានៃអនុសញ្ញានេសាទបាឡែនឆ្នាំ១៩៤៦ ។

៣- រដ្ឋាភិបាលសហរដ្ឋអាមេរិកត្រូវជូនដំណឹងទៅរដ្ឋាភិបាលដែលជាភាគីហត្ថលេខីឬរដ្ឋាភិបាលដែលជាសមាជិកនៃអនុសញ្ញានេសាទបាឡែន ឆ្នាំ១៩៤៦ ទាំងអស់ នូវរាល់ឯកសារផ្លូវការដែលបានតម្កល់ទុកនិងឯកសារផ្លូវការដែលទទួលបាន។

៤- ពិធីសារនេះត្រូវកំណត់ពេលបើកចំហសម្រាប់ចុះហត្ថលេខា ។ រយៈពេលបើកចំហសម្រាប់ចុះហត្ថលេខាមានរយៈពេល១៤(ដប់បួន) ថ្ងៃចាប់ពីថ្ងៃនេះតទៅ ។ បន្ទាប់ពីនោះទៅ គឺត្រូវបើកចំហសម្រាប់ការចូលរួមជាសមាជិក។

សាក្សីដែលបានចុះហត្ថលេខាដូចខាងក្រោមនេះ បានផ្តល់សិទ្ធិស្របច្បាប់ចំពោះការចុះហត្ថលេខាលើពិធីសារនេះ ។

ធ្វើនៅរដ្ឋធានីវ៉ាស៊ីនតោននាថ្ងៃទីដប់ប្រាំបួនខែវិច្ឆិកាឆ្នាំមួយពាន់ប្រាំបួនរយហាសិបប្រាំមួយ។ ច្បាប់ដើមនៃពិធីសារនេះជាភាសាអង់គ្លេស ត្រូវតម្កល់ទុកនៅរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកត្រូវបញ្ជូនឯកសារថតចម្លងដោយមានបញ្ជាក់ជាផ្លូវការទៅរដ្ឋាភិបាលដែលជាភាគីហត្ថលេខីឬរដ្ឋាភិបាលដែលចូលជាសមាជិកនៃអនុសញ្ញានេសាទបាឡែនឆ្នាំ១៩៤៦ ទាំងអស់ ។

## ហត្ថលេខី

១- សម្រាប់ប្រទេសឈីលី (Chile): Augustin R. Edwards

២- សម្រាប់ប្រទេសប៉េរូ (Peru): Carlos Rotalde

៣- សម្រាប់ប្រទេសអាហ្សង់ទីន (Argentina): Oscar Ivanissevich, José Manuel Moneta, Guillermo Brown, Pedro H. Bruno Videla

៤- សម្រាប់ប្រទេសដាណឺម៉ាក (Denmark): Peter Friedrich Erichsen

៥- សម្រាប់សហភាពសាធារណៈរដ្ឋសង្គមនិយមសូវៀត (The Union of Soviet Socialist Republics): Alexander S. Bogdanov, Eugine I. Nikishin

៦- សម្រាប់ប្រទេសអូស្ត្រាលី (Australia): Francis F. Anderson

៧- សម្រាប់ប្រទេសបារាំង (France): Francis Lacoste

៨- សម្រាប់ចក្រភពអង់គ្លេសនិងប្រទេសអៀកឡង់ខាងជើង (The United Kingdom of Great Britain and Northern Ireland): A.T.A. Dobson, J. Thomson

៩- សម្រាប់ប្រទេសប្រេស៊ីល (Brazil): Paulo Fróes da Cruz

១០- សម្រាប់ប្រទេសហូឡង់ (The Netherlands): Guy Richardson Powles

១១- សម្រាប់សហរដ្ឋអាមេរិក (The United States of America): Remington Kellogg, Ira N. Gabrielson, William E.S. Flory

១២- សម្រាប់ប្រទេសកាណាដា (Canada): H.H. Wrong, H.A. Scott

១៣- សម្រាប់ប្រទេសញ៉ូវហ្សេលែន (New Zealand): Birger Bergersen

១៤- សម្រាប់សហព័ន្ធអាហ្វ្រិកខាងត្បូង (The Union of South Africa): H.T. Andrews

# THE PROTOCOL

**Washington, 19th November 1956**

Protocol to the International Convention for the Regulation of Whaling Signed at Washington under date of December 2, 1946

The Contracting Governments to the International Convention for the Regulation of Whaling signed at Washington under date of 2nd December, 1946 which Convention is hereinafter referred to as the 1946 Whaling Convention, desiring to extend the application of that Convention to helicopters and other aircraft and to include provisions on methods of inspection among those Schedule provisions which may be amended by the Commission, agree as follows:

## Article I

Subparagraph 3 of the Article II of the 1946 Whaling Convention shall be amended to read as follows:

"3. 'whale catcher' means a helicopter, or other aircraft, or a ship, used for the purpose of hunting, taking, killing, towing, holding on to, or scouting for whales."

## Article II

Paragraph 1 of Article V of the 1946 Whaling Convention shall be amended by deleting the word "and" preceding clause (h), substituting a semicolon for the period at the end of the paragraph, and adding the following language: "and (i) methods of inspection".

## Article III

1. This Protocol shall be open for signature and ratification or for adherence on behalf of any Contracting Government to the 1946 Whaling Convention.

2. This Protocol shall enter into force on the date upon which instruments of ratification have been deposited with, or written notifications of adherence have been received by, the Government of the United States of America on behalf of all the Contracting Governments to the 1946 Whaling Convention.

3. The Government of the United States of America shall inform all Governments signatory or adhering to the 1946 Whaling Convention of all ratifications deposited and adherences received.

4. This Protocol shall bear the date on which it is opened for signature and shall remain open for signature for a period of fourteen days thereafter, following which period it shall be open for adherence.

IN WITNESS WHEREOF the undersigned, being duly authorized, have signed this Protocol.

DONE in Washington this nineteenth day of November, 1956, in the English Language, the original of which shall be deposited in the archives of the Government of the United States of America. The Government of the United States

of America shall transmit certified copies thereof to all Governments signatory or adhering to the 1946 Whaling Convention.

**SIGNATORIES:**

- FOR CHILE: Augustín R. Edwards
- FOR PERU: Carlos Rotalde
- FOR ARGENTINA: Oscar Ivanissevich, José Manuel Moneta, Guillermo Brown, Pedro H. Bruno Videla
- FOR DENMARK: Peter Friedrich Erichsen
- FOR THE UNION OF SOVIET SOCIALIST REPUBLICS: Alexander S. Bogdanov, Eugine I. Nikishin
- FOR AUSTRALIA: Francis F. Anderson
- FOR FRANCE: Francis Lacoste
- FOR THE UNITED KINGDOM OF GREAT BRITAIN AND NORTHERN IRELAND: A.T.A. Dobson, J. Thomson
- FOR BRAZIL: Paulo Fróes da Cruz
- FOR THE NETHERLANDS: Guy Richardson Powles
- FOR THE UNITED STATES OF AMERICA: Remington Kellogg, Ira N. Gabrielson, William E.S. Flory
- FOR CANADA: H.H. Wrong, H.A. Scott
- FOR NEW ZEALAND: Birger Bergersen

FOR THE UNION OF SOUTH AFRICA: H.T. Andrews

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១១០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ

**ក.ដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី **ឆន់ ម៉ុនគា** អត្តលេខ ០០០៨៤៩

២-ឧត្តមសេនីយ៍ត្រី **ពេជ្រ ចាយ** អត្តលេខ ០០០៧៥១

**ខ.ដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមនាវីត្រី**

-វរនាវីឯក **សុខ ជាទី** អត្តលេខ ០០៤៩៥២

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស. ១២១២. ១១០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible] រដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១១០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០០/១១ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីច្បាប់បន្ថែមលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៦/០២៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ស្តីពីលក្ខន្តិកៈដោយឡែកមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២

ROYAUME DU CAMBODGE
LE MINISTRE ... PALAIS ROYAL
ព្រះបរមរាជវាំង

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១:**

ត្រូវបានបង្កើត សញ្ញាសក្តិ ឯកសណ្ឋាន និងកន្លាស់រូបសញ្ញាសម្រាប់សម្គាល់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ។

**មាត្រា ២:**

សញ្ញាសក្តិ ឯកសណ្ឋាន និងកន្លាស់រូបសញ្ញាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនេះ សម្រាប់ប្រើនៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ។

## ជំពូកទី២

## សញ្ញាសក្តិ

**មាត្រា ៣:**

សញ្ញាសក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ រួមមានសក្តិលើស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ ដែលត្រូវបានកំណត់ដូចតទៅ៖

**១ - សក្តិលើស្មា**

មានផ្ទៃកម្ញីពណ៌ខ្មៅ។ នៅផ្ទៃកកណ្តាលនៃតួសក្តិនេះ មានរូបសញ្ញាអាជ្ញាធរសវនកម្មជាតិពណ៌មាស ផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌មាសមួយ និងផ្នែកខាងក្រោមមានក្បាច់ដកចន្ទន៍មួយរំលេចដោយក្បាច់អង្គរបួនសន្លឹកពណ៌មាសនិងរូបផ្កាឈូកពីរទងពណ៌មាស ហើយមានក្បាច់គ្របកឈូកពណ៌មាសតម្រៀបជាខ្សែព័ទ្ធជុំវិញនៅគែមតួសក្តិមានខ្សែពួរវេញពណ៌មាសចំនួនបីខ្សែព័ទ្ធជុំវិញសម្រាប់សម្គាល់ឋានន្តរសក្តិសវនករដើមខ្សែពិសេស ចំនួនពីរខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិសវនករដើមខ្សែ និងចំនួនមួយខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិសវនករ។

ខ្នាតសក្តិលើស្មាត្រូវបានកំណត់ដូចខាងក្រោម៖

- បាតក្រោមប្រវែង៦សង់ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង៤,៨០សង់ទីម៉ែត្រ កំពូលរាងកោង
- បណ្តោយពីលើដល់បាតក្រោមប្រវែង១៣សង់ទីម៉ែត្រ។

**២ - សក្តិចុងកអាវ**

មានផ្ទៃកម្ញីពណ៌ខ្មៅ។ មានរចនាតុបតែងដោយក្បាច់អង្គរពណ៌មាស និងមានរូបសញ្ញាអាជ្ញាធរសវនកម្មជាតិពណ៌មាសនៅខាងដើម។ មានក្បាច់គ្របកឈូកពណ៌មាសតម្រៀបជាខ្សែព័ទ្ធជុំវិញរបទាំងពីរខាង។ នៅគែមខាងលើនិងចំហៀងខាងមុខ មានខ្សែពួរវេញពណ៌មាសចំនួនបីខ្សែព័ទ្ធជុំវិញសម្រាប់សម្គាល់

ហានន្តរសក្តិសវនករដើមខ្សែពិសេស ចំនួនពីរខ្សែសម្រាប់សម្គាល់ហានន្តរសក្តិសវនករដើមខ្សែ និងចំនួនមួយខ្សែសម្រាប់សម្គាល់ហានន្តរសក្តិសវនករ។

ខ្នាតសក្តិចុងកអាវត្រូវកំណត់ដូចខាងក្រោម៖

- រាងប្រលេឡូក្រាម
- ជ្រុងវែងប្រវែង១០,៥០សង់ទីម៉ែត្រ
- ជ្រុងខ្លីប្រវែង៨សង់ទីម៉ែត្រ។

**៣ - សក្តិចុងដៃអាវ**

មានផ្ទៃកម្ពីពណ៌ខ្មៅ។ នៅផ្ទៃកកណ្តាលនៃតួសក្តិនេះ មានរូបសញ្ញាអាជ្ញាធរសវនកម្មជាតិពណ៌មាស រំលេចដោយក្បាច់អង្គរពណ៌មាសនៅសងខាង។ មានក្បាច់គ្របកឈូកពណ៌មាសតម្រៀបជាខ្សែព័ទ្ធជុំវិញ។ នៅគែមខាងលើនិងចំហៀងសងខាង មានខ្សែពួរវេញពណ៌មាសចំនួនបីខ្សែសម្រាប់សម្គាល់ហានន្តរសក្តិសវនករដើមខ្សែពិសេស ចំនួនពីរខ្សែសម្រាប់សម្គាល់ហានន្តរសក្តិសវនករដើមខ្សែ និងចំនួនមួយខ្សែសម្រាប់សម្គាល់ហានន្តរសក្តិសវនករ។

ខ្នាតសក្តិចុងដៃអាវត្រូវបានកំណត់ដូចខាងក្រោម៖

- រាងចតុកោណកែង
- បណ្តោយប្រវែង៣៣សង់ទីម៉ែត្រ ចំពោះបុរស និងប្រវែងពី២៥ទៅ២៨សង់ទីម៉ែត្រ អាស្រ័យលើទំហំខ្លួនរបស់ស្ត្រី
- ទទឹងប្រវែង១០,៥០សង់ទីម៉ែត្រ។

រូបសក្តិលើស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវនេះ មានដូចក្នុងឧបសម្ព័ន្ធទី១ ទី២ និងទី៣នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៣
## ឯកសណ្ឋាននិងការប្រើប្រាស់

**មាត្រា ៤:**

ឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិត្រូវបានកំណត់តាមប្រភេទដូចខាងក្រោមនេះ៖

**១ - ឯកសណ្ឋានផ្លូវការ**

**ក - ចំពោះបុរស**

- អាវកុតពណ៌សដៃវែង កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវទាំងសងខាងមានសក្តិតាមហានន្តរសក្តិ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិ មានហោប៉ៅចោះ មានគម្របរាងស្លឹកពោធិ៍ខាងលើចំនួនពីរ និងខាងក្រោមចំនួនពីរ ហើយនៅលើគម្របហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស។ ចុងដៃអាវមានសក្តិតាមហានន្តរសក្តិ អាវបិទឡេវមុខ មានដាក់ឡេវរូបព្រះសង្ហារពណ៌មាសចំនួនប្រាំពីរ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

- ខោជើងវែងពណ៌ស ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ។

**ខ - ចំពោះស្ត្រី**

-អាវជីបរាង ពណ៌ស កត្រង់ គ្មានផែកខ្នង បិទឡេវមុខ ចុងកអាវទាំងសងខាង មានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិ ដៃអាវរាងវែងត្រឹមកដៃ ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ និងអាវមានដាក់ឡេវរូបព្រះសង្ខារពណ៌មាសចំនួនប្រាំ។

-សំពត់សម្លុយធ្វើពីផាមួងពណ៌ខៀវចាស់ មានសម្រុងលើភ្លែកគោរ ស្បែកជើងអេសស្កាប៉ាងឃ្លុបមុខ និងកែងជិតពណ៌ខ្មៅ និងស្រោមជើងពណ៌សាច់។

រូបឯកសណ្ឋានផ្លូវការបុរសនិងស្ត្រីមានដូចក្នុងឧបសម្ព័ន្ធទី៤នៃព្រះរាជក្រឹត្យនេះ។

**២ - ឯកសណ្ឋានប្រពៃណីជាតិ**

**ក - ចំពោះបុរស**

- អាវកុកពណ៌សដៃវែង កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវទាំងសងខាងមានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិ មានហោប៉ៅចោះ មានគម្របរាងស្លឹកពោធិ៍ខាងលើចំនួនពីរ និងខាងក្រោមចំនួនពីរ ហើយនៅលើគម្របហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ខារពណ៌មាស។ ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ អាវបិទឡេវមុខ មានដាក់ឡេវរូបព្រះសង្ខារពណ៌មាសចំនួនប្រាំពីរ។

- សំពត់ផាមួងចងក្បិនពណ៌តាមថ្ងៃ ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅដល់ជង្គង់។

**ខ - ចំពោះស្ត្រី**

- អាវជីបរាង ពណ៌ស ដៃអាវត្រឹមកដៃ កវៀលមូល ខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិត ១,៥សង់ទីម៉ែត្រ និងស្មាឃ្លាតពីគល់កប្រមាណពី២,៥ទៅ៣សង់ទីម៉ែត្រ អាស្រ័យលើទំហំខ្លួនរបស់ស្ត្រី។ គ្មានសក្តិស្មានិងសក្តិចុងកអាវ ប៉ុន្តែមានសក្តិចុងដៃអាវទាំងសងខាង តាមឋានន្តរសក្តិ។

- ក្រមាពានាធ្វើពីសូត្រ ដែលមានផ្ទៃពណ៌ខ្ចីជាងសំពត់ ចាក់ជាយតាមបណ្តោយនិងទទឹងក្រមាដោយសូត្រពណ៌ចាស់ដូចសំពត់ តាមក្បាច់ឯកភាព ឬក្រមាសូត្រពណ៌ស៊ីនួន តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ និងមានកន្លាស់រូបសញ្ញាអាជ្ញាធរសវនកម្មជាតិ សម្រាប់ខ្ទាស់ក្រមាពានា។

- សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ស្បែកជើងអេសស្កាប៉ាងឃ្លុបមុខនិងកែងជិត ពណ៌ស ស្រោមជើងពណ៌សាច់ កាបូបយួរដៃពណ៌ស សម្រាប់ពេលព្រឹកដល់ថ្ងៃត្រង់ និងស្បែកជើងអេសស្កាប៉ាងពណ៌ខ្មៅ ស្រោមជើងពណ៌សាច់ កាបូបយួរដៃពណ៌ខ្មៅ សម្រាប់ពេលល្ងាចលើកលែងតែពិធីដែលប្រព្រឹត្ត [illegible]ញមួយថ្ងៃ។

រូបឯកសណ្ឋានប្រពៃណីជាតិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៥នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ៥:**

ការប្រើឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិត្រូវបាន កំណត់ដូចខាងក្រោម៖

- ឯកសណ្ឋានផ្លូវការសម្រាប់ប្រើក្នុងពិធីបុណ្យជាតិនិងពិធីផ្លូវការផ្សេងៗ
- ឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើក្នុងពិធីបុណ្យប្រពៃណីជាតិនិងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬកន្លែងផ្សេងៗ។

## ជំពូកទី៤

## កន្លាស់រូបសញ្ញា

**មាត្រា ៦:**

កន្លាស់រូបសញ្ញាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ គឺជារូបសញ្ញាអាជ្ញាធរសវនកម្មជាតិ ធ្វើពីស្ពាន់ ជ្រលក់ទឹកមាស មានទំហំទទឹង២,៤សង់ទីម៉ែត្រ និងកំពស់៣សង់ទីម៉ែត្រ សម្រាប់ប្រើនៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ។

រូបកន្លាស់រូបសញ្ញាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនេះ មានដូចក្នុងឧបសម្ព័ន្ធទី៦ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៥

## របបកំណត់សញ្ញាសក្តិ ឯកសណ្ឋាន និងកន្លាស់រូបសញ្ញា

**មាត្រា ៧:**

ការចំណាយសម្រាប់ផលិតសញ្ញាសក្តិ ឯកសណ្ឋាន និងកន្លាស់រូបសញ្ញា និងសម្ភារៈផ្សេងៗទៀត នៃអាជ្ញាធរសវនកម្មជាតិជាបន្ទុកថវិការបស់រដ្ឋ។

**មាត្រា ៨:**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មត្រូវបានផ្គត់ផ្គង់ឲ្យនូវសញ្ញាសក្តិ ឯកសណ្ឋានផ្លូវការ ឯកសណ្ឋានប្រពៃណីជាតិ កន្លាស់រូបសញ្ញា និងសម្ភារៈផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ មួយសម្រាប់ម្នាក់ សម្រាប់ប្រើរយៈពេលប្រាំឆ្នាំ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**មាត្រា ១០.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១២១២.១១១៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ... ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី ... រដ្ឋាភិបាល

**សយ សុខា**

៦/៦

## សញ្ញាសក្តិសវនករដើមខ្សែពិសេស

ឧបសម្ព័ន្ធទី១នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១១០៥
ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីសញ្ញាសក្តិនិងឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ



សក្តិករអាវ



សក្តិលើស្មា



សក្តិចុងដៃអាវ

១/៤

**សញ្ញាសក្តិសវនករដើមខ្សែ**

ឧបសម្ព័ន្ធទី២នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១១០៥
ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីសញ្ញាសក្តិនិងឯកសណ្ឋានសម្រាប់
មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ



សក្តិកអាវ



សក្តិលើស្មា



សក្តិចុងដៃអាវ

## សញ្ញាសក្តិសវនករ

ឧបសម្ព័ន្ធទី៣នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១២០៥
ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីសញ្ញាសក្តិនិងឯកសណ្ឋាន
សម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ



សក្តិកអាវ



សក្តិលើស្មា



សក្តិចុងដៃអាវ

៧ ³/₈



## ឯកសណ្ឋានផ្លូវការ

ឧបសម្ព័ន្ធ ទី៤នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១១០៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១២ស្តីពីសញ្ញាសក្តិនិងឯកសណ្ឋាន សម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ

១៧/



### ឯកសណ្ឋានប្រពៃណី

ឧបសម្ព័ន្ធ ទី៥នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១១០៥ ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីសញ្ញាសក្តិនិងឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌ មន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ

**ឧបសម្ព័ន្ធ ទី៦នៃព្រះរាជក្រឹត្យលេខ...នស/រកត/១២១២/១១០៥ ចុះថ្ងៃទី..២៩..ខែ..ធ្នូ......ឆ្នាំ២០១២.ស្តីពីសញ្ញាសក្តិនិងឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ**



# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១១០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វេហ្គារី ប៉េងអាន** (WEE GARY PENG-ANN) ជនជាតិអង់គ្លេស សញ្ជាតិអង់គ្លេស កើតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៦៣ នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស ដោយប្តូរឈ្មោះជា **ហុង ឆាយ** (HONG CHHAY )។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការស. ១២១២. ១១២០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១២

លេខ: ១០៦១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១១០៧

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្សង់ ប៊ូ** (ZHANG BUOU) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧៣ នៅខេត្តស៊ីជាំង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរស.១២១២.១១២១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១២

លេខៈ១០[illegible]៧ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ[illegible] ឆ្នាំ២០១២

**អគ្គលេខាធិការនៃទីស្ដីការគណៈរដ្ឋមន្ត្រី**

**ស៊ឹយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១១០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជនចំនួន ០៤ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្សរ៍៖

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **សេង ឧុទ្ធី**
២- ឯកឧត្តម ឧត្តមសេនីយ៍ទោ **គន់ សុភា**
៣- ឯកឧត្តម ឧត្តមសេនីយ៍ទោ **សោ ណារ៉ុង**
៤- ឯកឧត្តម ឧត្តមសេនីយ៍ទោ **សៅ សៀប**

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រល-១២១២.១១២២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

លេខ:៧០៥៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១១១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានៈជូនឯកឧត្តម **គាត យុនម៉ុង** ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៩. ១២១២. ១១២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២

លេខ ១៩ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០០១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

**នូវ**

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

ចំពោះ

**ឧកញ៉ា ឈន ថារី**

សប្បុរសជននៅខេត្តកំពង់ចាម ដែលមានគុណបំណាច់ខ្ពស់ បានបរិច្ចាគធនធានផ្ទាល់ខ្លួន ចំនួន ៤៩៨.០០០ ដុល្លារអាមេរិក សំរាប់ចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា អប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ស្ថិតនៅខេត្តកំពង់ចាម និងអគារសិក្សាចំនួន ០៣ខ្នង នៅខេត្តស្វាយរៀង សម្រេចបានលទ្ធផលល្អប្រសើរ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៤-១៣០១.០០១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣

លេខ ១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ
ចំនួន ១០ រូប មានស្នាដៃល្អក្នុងការបម្រើជាតិមាតុភូមិ កន្លងមក

នូវ

## គ្រឿងឥស្សរិយយសជាតូបការ

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ឯក | **ជ័យ** | **សុន** | អត្តលេខ ០០០៧១៦ |
| ២-ឧត្តមសេនីយ៍ឯក | **ចាន់** | **សុខុម** | អត្តលេខ ០០០២៨៦ |
| ៣-ឧត្តមសេនីយ៍ឯក | **ខឿ** | **ពិសេន** | អត្តលេខ ០០០៣៥៧ |
| ៤-ឧត្តមសេនីយ៍ឯក | **តេង** | **ឈួន** | អត្តលេខ ០០០៣១៧ |
| ៥-ឧត្តមនាវីឯក | **សៅ** | **សារិន** | អត្តលេខ ០០០២៩៧ |
| ៦-ឧត្តមនាវីឯក | **មាស** | **ថង** | អត្តលេខ ០០០០៩៤ |
| ៧-ឧត្តមនាវីឯក | **ម៉ាន់** | **ស៊ីវណ្ណា** | អត្តលេខ ០០១១១៨ |
| ៨-ឧត្តមនាវីឯក | **អ៊ុក** | **សីហា** | អត្តលេខ ០០០៨៨០ |
| ៩-ឧត្តមនាវីឯក | **ស្រ៊ុន** | **សារឿន** | អត្តលេខ ០០០៩៣០ |
| ១០-ឧត្តមនាវីឯក | **ខួន** | **យោធ** | អត្តលេខ ០០១១១៥ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧ - ១៣០១.០០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៣

លេខៈ ១៤ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៣
អគ្គលេខាធិការ រាជរដ្ឋាភិបាល
សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនិងមន្ត្រីអន្តរក្រសួង ចំនួន៤៧រូប មានគុណបំណាច់ និងស្នាដៃល្អក្នុងការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤៤ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៥ ខែសីហា ដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០១២ នៅខេត្តសៀមរាប សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

ឯកឧត្តម ប៉ាន សូរស័ក្តិ

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសិរីវឌ្ឍន៍**

១-ឯកឧត្តម ឈួន ដារ៉ា
២-ឯកឧត្តម ម៉េង សុធី
៣-លោកជំទាវ តឹកវ៉េត គំរ៉ង
៤-ឯកឧត្តម ស្រ៊ុន តារា
៥-ឯកឧត្តម យឹម សិរីវង្ស
៦-ឯកឧត្តម សុខ សុភ័ក្ត្រ
៧-ឯកឧត្តម ពេជ ឫទ្ធី
៨-ឯកឧត្តម ស៊ាង ថៃ
៩-ឯកឧត្តម គឹម គុណវឌ្ឍន៍
១០-ឯកឧត្តម មាន សុភា
១១-ឯកឧត្តម ស៊ា រុតសាន
១២-ឯកឧត្តម សឹន សុថា

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

១-ឯកឧត្តម ភាន ច័ន្ទមេត្តា
២-លោកជំទាវ ចម និម្មល
៣-លោក អ៊ុំ សុថា
៤-លោក ផាន អូន

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**

១-លោក រំចេក សុវ៉ាវី
២-លោក ម៉ែន សុទិជាតិ

**ង-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសិរីវឌ្ឍន៍**

១-ឯកឧត្តម យូ ស៊ុនឡុង
៣-ឯកឧត្តម ជា ម៉ន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៤-ឯកឧត្តម ជួន សុវណ្ណ

៥-ឯកឧត្តម ឆន្ទ សុខា

៦-ឯកឧត្តម ជឹម សារឿន

៧-ឯកឧត្តម ធិត្យ ចន្ថា

៨-ឯកឧត្តម អ៊ុច ជំនោរ

៩-លោក ក្រៃ ស៊ិនហៀង

១០-លោក ហ៊ឹម ហ៊ាន

១១-លោក ភាំង សុជាតិ

១២-លោក សាន់ សារី

៤-ឯកឧត្តម នូ ផល្លា

១៣-លោក ម៉ន សាម៉ុន

១៤-លោក ឃួន សំណាង

១៥-លោក ម៉ម ស្រីមចណ្ណា

១៦-លោក អន សារិទ្ធ

១៧-លោក ម៉ក់ សំអុល

១៨-លោក យេត រាហ្សាក់

១៩-លោក សត ណាឌី

**ច-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា**

១-លោក សាន តិរុណ្ណា

២-លោក មុំ ចន្ទតារ៉ា

៣-លោក គ្រុស សារ៉ាត់

៤-លោកស្រី ស៊ិន ហួន

៥-លោក កែវ ពេជ្ជនិម្មល

៦-លោក នូ ម៉ុនថា

៧-លោក នូ គន្ធា

៨-លោក ឌី ឡុង

៩-លោក ភាន់ សម្បត្តិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៩-១៣០១.០០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣

លេខ ០៤ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរង[illegible]រដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

**នូវ**

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

ចំពោះ

ឧបាសក **គីម គៀង**

ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង

សមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅខេត្តស្វាយរៀង ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរកទ.១៣០១.០០៤

លេខ: ០៦ ច.ល

**ចំលងចេញពីច្បាប់ដើម**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៣*

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១៣

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០៧. អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

**ការកាត់ដីទំហំសរុប ១១.៥០០,៥០ ហិកតា នៅស្រុកគាស់ក្រឡ ស្រុកបាណន់ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលក្នុងនោះ កាត់ចេញពីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃនាមជូនសំ ពីព្រៃសម្បទានយូរីសោគរ និង ពីព្រៃសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋ ២.៧០៧ គ្រួសារ និង រក្សាទុកមួយចំណែកជាដីភ្នំ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/០៤៣ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៦៧៤ ខបប ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.**

- ត្រូវបានកាត់ដីទំហំសរុប ១១.៥០០,៥០ ហិកតា ដែលក្នុងនោះ (១) ទំហំ ៤.៣៩៧ ហិកតា កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ (២) ទំហំ ១៦៣២,៥០ ហិកតា ពីព្រៃរនាមដូនសំ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០១១៣ /០៤៣ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (៣) ទំហំ ១១៥ ហិកតា ពីព្រៃសម្បទានយូរីសាគរ និង (៤) ទំហំ ៥.៣៥៦ ហិកតា ពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ១១.៤១៩ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៨១,៥០ ហិកតា រក្សាទុកជាដីរដ្ឋ(ភ្នំ) នៅស្រុកគាស់ក្រឡ ស្រុកបាណន់ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានទំហំ និងចំនួនគ្រួសារ ស្ថិតនៅក្នុងភូមិសាស្រ្តដូចខាងក្រោម៖

**១.១. ឃុំព្រះផុស ស្រុកគាស់ក្រឡ**

- ផ្ទៃដីទំហំសរុប ១.៩៦២ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦០ គ្រួសារ នៅភូមិព្រៃចក
- ផ្ទៃដីទំហំសរុប ២.៥៥០ ហិកតា ដែលក្នុងនោះ ទំហំ ១១៥ ហិកតា កាត់ចេញពីព្រៃសម្បទានយូរីសាគរ និង ទំហំ ២.៤៣៥ ហិកតា ពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ២.៤៦៨,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៧៧ គ្រួសារ និងទំហំ ៨១,៥០ ហិកតា រក្សាទុកជាដីរដ្ឋ(ភ្នំ) នៅភូមិតានូត

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ(១) នៃអនុក្រឹត្យនេះ។

**១.២. ឃុំស្ដៅ ស្រុកបាណន់**

- ផ្ទៃដីទំហំសរុប ២.៤១២ ហិកតា កាត់ចេញពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៣៥ គ្រួសារ នៅភូមិបឹងក្រសាល
- ផ្ទៃដីទំហំសរុប ២.៩៤៩ ហិកតា កាត់ចេញពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦២២ គ្រួសារ នៅភូមិបឹងប្រី

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

**១.៣. ឃុំបារាំងធ្លាក់ និងឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក**

- ផ្ទៃដីទំហំសរុប ៩១៩,៥០ ហិកតា កាត់ចេញពីព្រៃរនាមដូនសំ ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៥៥ គ្រួសារ នៅភូមិអូរជ្រៃ ឃុំបារាំងធ្លាក់
- ផ្ទៃដីទំហំសរុប ៧១៨ ហិកតា កាត់ចេញពីព្រៃរនាមដូនសំ ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥៨ គ្រួសារ នៅភូមិអូរធំ ឃុំភ្នំព្រឹក

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២.៧០៧ គ្រួសារ នៅស្រុកគាស់ក្រឡ ស្រុកបាណន់ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានទំហំ និងចំនួនគ្រួសារស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

**២.១. ឃុំព្រះផុស ស្រុកគាស់ក្រឡ**

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦០ គ្រួសារ នៅភូមិព្រៃចក
- ប្រទានកម្មទំហំ ២៩៦៨,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៧៧ គ្រួសារ នៅភូមិតាន្នូត

**២.២. ឃុំស្ដៅ ស្រុកបាណន់**

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៣៥ គ្រួសារ នៅភូមិបឹងក្រសាល
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦២២ គ្រួសារ នៅភូមិបឹងប្រី

**២.៣. ឃុំបារាំងធ្លាក់ និងឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក**

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៥៥ គ្រួសារ នៅភូមិអូរជ្រៃ ឃុំបារាំងធ្លាក់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥៨ គ្រួសារ នៅភូមិអូរធំ ឃុំភ្នំព្រឹក

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ឧបសម្ព័ន្ធ(១)នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ ការកាត់ដីទំហំសរុប ១១.៥០០,៥០ ហិកតា នៅស្រុកគាស់ក្រឡ ស្រុកបាណន់ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលក្នុងនោះ កាត់ចេញពីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃនៅជុំវិញ ពីព្រៃសម្បទានឃ្លីសោភ័ណ និង ពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន តាពីម៉ិច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋ ២.៧០៧ គ្រួសារ និង ទុកបម្រុងមួយចំណែកជាដីជាដីភ្នំ**






| ល.រ | X | Y |
|---|---|---|
| 1 | 316470 | 1403775 |
| 2 | 315854 | 1400802 |
| 3 | 315156 | 1400502 |
| 4 | 314972 | 1400086 |
| 5 | 314170 | 1400324 |
| 6 | 313674 | 1399951 |
| 7 | 313637 | 1399265 |
| 8 | 312615 | 1399143 |
| 9 | 312750 | 1393234 |
| 10 | 310557 | 1393332 |
| 11 | 310472 | 1393038 |
| 12 | 309045 | 1393363 |
| 13 | 309278 | 1393785 |
| 14 | 307802 | 1394097 |
| 15 | 307925 | 1394906 |
| 16 | 309676 | 1394557 |
| 17 | 309654 | 1401049 |
| 18 | 310746 | 1401144 |
| 19 | 310868 | 1402553 |
| 20 | 311401 | 1402699 |
| 21 | 311175 | 1403422 |
| 22 | 311793 | 1403551 |
| 23 | 311811 | 1403955 |
| 24 | 312816 | 1403808 |
| 25 | 313471 | 1403906 |
| 26 | 313526 | 1404610 |
| 27 | 312883 | 1404549 |
| 28 | 312858 | 1404861 |
| 29 | 313489 | 1404959 |
| 30 | 313471 | 1405418 |
| 31 | 314077 | 1405504 |
| 32 | 315240 | 1403893 |

ចំនុចនិយាមការ

**ប្រព័ន្ធកូអរដោនេ :**

តំបន់ទី : 48N

ចំណោលផែនទី : UTM

ទិន្នន័យយោង : WGS1984

**ប្រភពទិន្នន័យ:**

ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ

គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២

**គម្របព្រៃឈើ**

ព្រៃស្រោង

ព្រៃល្បោះ

ព្រៃពាក់កណ្តាលស្រោង

ដីមិនមែនព្រៃ

ព្រំប្រទល់ដីស្នើសុំ

ព្រំប្រទល់ដីភ្នំ

(ផ្ទៃដីភ្នំសរុបចំនួន៨១.៥ហិកតា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៧ អនក្រ-បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកាត់ដីទំហំ ៤៨៦,៣៨១៣ ហិកតា នៅស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជា ច័ន្ទរិទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០៤ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្តល់សិទ្ធិលើក្បាលដី**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០១៧ របក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ៩៨៦,៣៨១៣ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជា ច័ន្ទរិទ្ធិ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ៩៦៤.៩៣៦៦ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២១,៤៤៤៧ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិឡៃ ឃុំលំជ័រ ស្រុកអូរយ៉ាដាវ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិឡៃ ឃុំលំជ័រ ស្រុកអូរយ៉ាដាវ ។

**មាត្រា ៣.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៧១ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១០២ គ្រួសារ នៅភូមិឡៃ ឃុំលំជ័រ ស្រុកអូរយ៉ាដាវ។

**មាត្រា ៤ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីទំហំ ២៤៣,៥៩៣២ ហិកតា នៅស្រុកវើនសៃ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៨ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្តល់សិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០១០ របក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ២៤៣,៥៩៣២ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន ដើម្បីធ្វើប្រទានកម្ម ទំហំ ២១៧,១១៣៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៨ គ្រួសារ និងទំហំ ២៦,៤៧៩៨ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិហ្យាំង ឃុំប៉ុង ស្រុកវើនសៃ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិហ្យាំង ឃុំប៉ុង ស្រុកវើនសៃ។

**មាត្រា ៣.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៩៤ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៧៧ គ្រួសារ នៅភូមិហ្យាំង ឃុំប៉ុង ស្រុកវើនសៃ។

**មាត្រា ៤ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីទំហំ ២៥៨,១៧៣៣ ហិកតា នៅស្រុកបរកែវ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជា ច័ន្ទរិទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៧ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការផ្តល់សិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០១៥ របក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ២៥៨,១៧៣៣ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជាច័ន្ទរិទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ២៤៦,៦៩២៣ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១១,៤៨១០ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិកាចក់ ឃុំកក់ ស្រុកបរកែវ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិកាចក់ ឃុំកក់ ស្រុកបរកែវ ។

**មាត្រា ៣.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៧១ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៥៣ គ្រួសារ នៅភូមិកាចក់ ឃុំកក់ ស្រុកបរកែវ ។

**មាត្រា ៤ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១២៨,៤២៩៦ ហិកតា នៅស្រុកវើនសៃ ខេត្តរតនគិរី ចេញពីដី សម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេស ខេ ផ្លែនថេសិន ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការផ្តល់សិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០០៨ របក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ១២៨,៤២៩៦ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន ដើម្បីធ្វើប្រទានកម្ម ទំហំ ១១០,២១៤៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៨,២១៥៣ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិប៉ុង ឃុំប៉ុង ស្រុកវើនសៃ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិប៉ុង ឃុំប៉ុង ស្រុកវើនសៃ។

**មាត្រា ៣.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៩៤ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៣៦ គ្រួសារ នៅភូមិប៉ុង ឃុំប៉ុង ស្រុកវើនសៃ។

**មាត្រា ៤ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៣៧១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនកញ្ញា ឌួច សុគន្ធី ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៣៨៦-អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **លី ដារ៉ាវុទ្ធ** ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៣៨៣.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **ម៉ាង សុជាតិ** ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៣៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

